CHIP MONG PIPES

# ទុយោ ជីប ម៉ុង

## ទុកចិត្តដោយវិស្វករ

**ISO 9001:2015**








## លក្ខណៈពិសេស

- ធន់នឹងអុកស៊ីតកម្ម
- មិនមានសារធាតុពុល
- ស្រាល ងាយស្រួលបន្លាស់ទី
- មិនចម្លងអគ្គិសនី
- អនាម័យខ្ពស់
- ធន់នឹងកម្តៅ UV
- មិនកាន់ស្នឹម
- ផលិតតាមបទដ្ឋានអន្តរជាតិ ISO
- ធន់នឹងសម្ពាធទឹក និងកម្លាំងសង្កត់

CHIP MONG PIPES





**ក្រុមហ៊ុន ជីប ម៉ុង អ៊ីនដាស្ទ្រីស៍**

អាសយដ្ឋាន: អគារលេខ 137 ផ្លូវ ម៉ៅសេទុង សង្កាត់បឹងកេងកងទី 3 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

085 / 066 / 069 990 222

# អំពីក្រុមហ៊ុន

ក្រុមហ៊ុន ជីប ម៉ុង អ៊ីនដាស្ទ្រីស៍ គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធមួយនៅក្នុង ចំណោមក្រុមហ៊ុនបុត្រសម្ព័ន្ធជាច្រើនទៀតរបស់ ជីប ម៉ុង ដែលមាន កេរ្តិ៍ឈ្មោះល្បីខាងផ្គត់ផ្គង់សម្ភារៈសំណង់មានគុណភាពល្អជាមួយនឹង សេវាកម្មរហ័សទាន់ចិត្ត ដើម្បីចូលរួមអភិវឌ្ឍប្រទេសកម្ពុជាចាប់តាំងពី ទសវត្សរ៍ទី ៨០។

ក្រុមហ៊ុន ជីប ម៉ុង អ៊ីនដាស្ទ្រីស៍ បានទទួលការគាំទ្រយ៉ាងខ្លាំងរហូត អភិវឌ្ឍខ្លួនទៅជាក្រុមហ៊ុនក្នុងស្រុកដ៏ធំបំផុតមួយ ដោយសារការផ្ដល់នូវទំនុកចិត្តជូនអតិថិជនលើផលិតផលមានគុណភាពខ្ពស់ ពីវត្ថុធាតុដើមល្អៗ និងផ្អែកលើបច្ចេកវិទ្យាចុងក្រោយបង្អស់របស់ប្រទេស អ៊ីតាលី។

ជាមួយគ្នានេះដែរ ក្រុមហ៊ុន ជីប ម៉ុង អ៊ីនដាស្ទ្រីស៍  មានរោងចក្រផលិតទុយោ ជីប ម៉ុង ដែលបំពាក់នូវម៉ាស៊ីនទំនើបបំផុតពីប្រទេសអ៊ីតាលី ដែលមានសមត្ថភាពផលិតទុយោបាន 300Kg ក្នុង មួយម៉ោង ។  រោងចក្រទុយោ ជីប ម៉ុង មានផលិតទុយោ PVC, ទុយោ HDPE,  ទុយោស៊ក និងហ្គេនខ្សែភ្លើង CONDUIT & CORRUGATED  និងគ្រឿងតំណទុយោគ្រប់ប្រភេទ និងគ្រប់ខ្នាត។ ផលិតផលទុយោ ជីប ម៉ុង សុទ្ធតែឆ្លងកាត់ការតេស្តដោយសម្ពាធទឹក និងកម្តៅ, តេស្តដោយសង្កត់, និងតេស្តដោយទង្គិច ដើម្បីធានាថា ទុយោមានគុណភាពស្ថិត រឹងមាំ ធន់នឹងអាកាសធាតុ។ រោងចក្រផលិត ទុយោ ជីប ម៉ុង ទទួលបានវិញ្ញាបនបត្រ ISO 9001:2015 ស្តីពីប្រព័ន្ធគ្រប់គ្រងគុណភាពផងដែរ ។




# ស្តង់ដារផលិតផល

## គុណភាព៖

- ផលិតផលត្រូវបានពិនិត្យ និងធ្វើតេស្តគុណភាពជាច្រើនដំណាក់កាលក្នុងបន្ទប់ពិសោធន៍ដ៏ទំនើបដោយទទួលស្គាល់កម្រិត ISO ជាមួយនឹងវិជ្ជាជីវៈច្បាស់លាស់ មុននឹងបញ្ចេញលក់នៅលើទីផ្សារ។
- ការវេចខ្ចប់ទំនិញត្រូវបានធ្វើឡើងដោយម៉ាស៊ីនទំនើប ដើម្បីរក្សាបាននូវសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។
- ការរក្សាទុក  និងចរាចរទំនិញគឺធ្វើតាមប្រព័ន្ធគ្រប់គ្រងស្តុក ដែលជាបច្ចេកវិទ្យាចុងក្រោយបំផុត។

## សេវាកម្ម៖

- មានទំនួលខុសត្រូវខ្ពស់លើផលិតផលទាំងមុននិងក្រោយពេលដាក់លក់លើទីផ្សារ។
- មានលក់ និងផ្គត់ផ្គង់ទូទាំងប្រទេស។
- អ្នកប្រឹក្សា និងផ្តល់ព័ត៌មានអំពីផលិតផលប្រកបដោយវិជ្ជាជីវៈខ្ពស់។

## សមត្ថភាពពិសេសផ្សេងទៀត៖

- មានអ្នកជំនាញរង់ចាំជួយ និងរកដំណោះស្រាយរាល់បញ្ហាទុយោ។
- ការសិក្សាស្រាវជ្រាវបង្កើតការច្នៃប្រឌិតដើម្បីអភិវឌ្ឍផលិតផលស្របតាមបច្ចេកវិទ្យាទំនើប។




CS 094-2:2015
ISO 1452-2:2009
ទទួលស្គាល់គុណភាព ដោយ
វិទ្យាស្ថានស្តង់ដារជាតិ និងអន្តរជាតិ

# ទុយោទឹក ភីវីស៊ី ជីប ម៉ុង

## សម្រាប់ផ្គត់ផ្គង់ប្រព័ន្ធទឹក

ទុយោ ភីវីស៊ី ជីប ម៉ុង ពណ៌ខៀវ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងព្រះរាជាណាចក្រកម្ពុជា អំឡុងពេលដែលវិស័យសំណង់ ឧស្សាហកម្ម និងកសិកម្ម កំពុងមានការរីកចម្រើន។ ទុយោ ភីវីស៊ី ជីប ម៉ុង ទទួលបានការជឿជាក់ទុកចិត្ត ដោយសារមានលក្ខណៈពិសេសដូចជា មាំ ស្វិត ធន់នឹងអាកាសធាតុតំបន់ត្រូពិច មិនងាយស្លកពណ៌ មិនកាន់ស្លែ មិនចម្លងកម្តៅនិងអគ្គិសនីប្រើប្រាស់បានយូរអង្វែងដោយ មិនចាំបាច់មានការថែទាំ។ ដូចនេះហើយទើបអតិថិជនទូទាំងប្រទេសជឿជាក់ និងទុកចិត្តលើផលិតផលទុយោ ជីប ម៉ុង។



## គ្រឿងតំណទុយោ ជីប ម៉ុង





## លក្ខណៈពិសេសរបស់គ្រឿងតំណទុយោ ជីប ម៉ុង

### គ្រប់កម្រិត គ្រប់ហ៊ិន អាចប្រើប្រាស់ជាមួយនឹងទុយោគ្រប់ប្រភេទ

គ្រឿងតំណ ជីប ម៉ុង មានលក្ខណៈពិសេសជាងគេ គឺដោយសារតែផលិតផលយើងអាចយកទៅតភ្ជាប់ជាមួយទុយោ ភីវីស៊ី គ្រប់ម៉ាកបានយ៉ាងងាយស្រួលដោយមិនរលុង ឬចង្អៀតពេកឡើយ។

### ធន់នឹងកម្តៅ UV

ដោយមានការផ្សំវត្ថុធាតុដើមពី ទីតាញ៉ូម ឌីអុកស៊ីត (Titanium Dioxide) ធ្វើឱ្យទុយោ ជីប ម៉ុង មានភាពធន់បានល្អ ពីកាំរស្មី UV ដែលមិនធ្វើឱ្យទុយោហើរពណ៌ ឬផុយស្រួយឡើយ។

### ធន់នឹងអុកស៊ីតកម្ម

ទុយោ ជីប ម៉ុង ធន់នឹងអាល់កាឡាំង និងអាស៊ីតខ្សោយដែលមិនប៉ះពាល់ដល់ការបំលែងអុកស៊ីតកម្ម ជាអំណោយផលឱ្យទុយោប្រើបានយូរអង្វែង។

### អនាម័យ

ទុយោ ជីប ម៉ុង គឺជាផលិតផលរក្សានូវបទដ្ឋានអនាម័យខ្ពស់ មិនបង្កឱ្យមានក្លិន ឬប្តូរពណ៌ទឹកក្នុងទុយោឡើយ។

# ទុយោ ជីប ម៉ុង ពណ៌ខ្មៅ HDPE

ទុយោ ជីប ម៉ុង ពណ៌ខ្មៅ HDPE ត្រូវបានគេប្រើប្រាស់លើប្រព័ន្ធទឹកធំៗ ដូចជាប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសម្រាប់ទីក្រុង តំបន់សហគ្រាស គម្រោងអគារធំៗវិស័យកសិកម្ម។ល។ ទុយោ ជីប ម៉ុង ពណ៌ខ្មៅ HDPE ត្រូវបានផលិតឡើងដោយសម្រិតសម្រាំង ជាប់ធន់យូរអង្វែងពេលកប់ក្នុងដី  ងាយស្រួលបត់បែន និងតភ្ជាប់ ល្អបំផុតសម្រាប់ប្រព័ន្ធទឹកខ្នាតធំ និងចម្ងាយឆ្ងាយ។






## គ្រឿងតំណទុយោ ជីប ម៉ុង

### លក្ខណៈពិសេសរបស់គ្រឿងតំណទុយោ ជីប ម៉ុង

**គ្រប់កម្រិត គ្រប់ហ៊ុន សក្តិសមជាមួយនឹងទុយោគ្រប់ប្រភេទ**

គ្រឿងតំណទុយោ ជីប ម៉ុង ពណ៌ខ្មៅ HDPE មានលក្ខណៈពិសេសជាងគេ គឺដោយសារតែផលិតផលយើង អាចយកទៅអ៊ុតតភ្ជាប់ជាមួយទុយោ HDPE គ្រប់ម៉ាកបានយ៉ាងងាយស្រួលដោយមិនរលុង និងជាប់បានយូរអង្វែង។

**ធន់នឹងកម្តៅ UV**

ដោយមានការផ្សំវត្ថុធាតុដើមពីអឺរ៉ុប ធ្វើឱ្យគ្រឿងតំណទុយោ ជីប ម៉ុង ពណ៌ខ្មៅ HDPE មានសភាពធន់បានយ៉ាងល្អពីកាំរស្មី UV និងកម្តៅដែលមិនធ្វើឱ្យទុយោ ស្លក ឬហើរពណ៌ឡើយ។

**ធន់នឹងអុកស៊ីតកម្ម**

គ្រឿងតំណទុយោ ជីប ម៉ុង ពណ៌ខ្មៅ HDPE ធន់សារធាតុអាល់កាឡាំង និងអាស៊ីតខ្សោយ ដែលមិនប៉ះពាល់ដល់ការបំលែងអុកស៊ីតកម្ម ជាអំណោយផលដល់ទុយោប្រើបានយូរអង្វែង។

**ធន់ការកប់ក្រោមដី**

គ្រឿងតំណទុយោ ជីប ម៉ុង ពណ៌ខ្មៅ HDPE ផ្សំពីសារធាតុពិសេស ដែលធ្វើឱ្យមានភាពស៊ាំជាមួយការកប់ក្រោមដី សក្តិសមល្អបំផុតសម្រាប់ រចនាប្រព័ន្ធទឹកសម័យទំនើបបច្ចុប្បន្ន។

**អនាម័យ**

ទុយោ ជីប ម៉ុង  ពណ៌ខ្មៅ HDPE គឺជាផលិតផលរក្សានូវបទដ្ឋានអនាម័យខ្ពស់ មិនបង្កឱ្យមានក្លិន ឬប្តូរពណ៌ទឹកក្នុងទុយោឡើយ។



# ទុយោស៊ីក និង ហ្គេនខ្សែភ្លើង ជីប ម៉ុង (CONDUIT & CORROGATED)

ទុយោស៊ីក និងហ្គេនខ្សែភ្លើង ជីប ម៉ុង ត្រូវបាននិយមប្រើប្រាស់យ៉ាងទូលំទូលាយ តាមការដ្ឋានសំណង់តូចធំ ព្រមទាំងគម្រោងប្រព័ន្ធអគ្គិសនីជាតិ និងអន្តរជាតិទូទាំងប្រទេស។ នេះក៏ដោយសារតែ ទុយោស៊ីក និងហ្គេនខ្សែភ្លើង ជីបម៉ុងមានគុណភាពល្អ ដុតមិនឆេះ និងមានសមត្ថភាពការពារការបង្កអគ្គិភ័យ ដែលផ្តើមចេញពីប្រព័ន្ធអគ្គិសនី។ បច្ចេកវិទ្យា អ៊ីតាលី បានធ្វើឱ្យទុយោស៊ីក និងហ្គេនខ្សែភ្លើង ជីប ម៉ុង រឹងមាំជាងផលិតផលដទៃ និងធន់ទ្វេដង ដូច្នេះហើយទើបវាត្រូវបានទទួលស្គាល់ដោយអ្នកជំនាញ និងវិស្វករ។






## លក្ខណៈពិសេសរបស់ទុយោស៊ីក និង ហ្គេនខ្សែភ្លើង ជីប ម៉ុង (CONDUIT & CORRUGATED)

### ជាប់ស្វិតប្រើប្រាស់បានយូរអង្វែង

បង្កើតឡើងដោយប្រើប្រាស់វត្ថុធាតុដើមល្អពីអឺរ៉ុប បច្ចេកវិទ្យាចុងក្រោយពីប្រទេសអ៊ីតាលី ដែលធានាបាននូវគុណភាពស្វិត ជាប់ធន់ មិនងាយប្រេះ ឬដាច់ ប្រើប្រាស់បានយូរអង្វែង។

### ដុតមិនឆេះ ការពារអគ្គិភ័យ

ទុយោស៊ីក និងហ្គេនខ្សែភ្លើង ជីប ម៉ុង ផ្សំឡើងដោយសារធាតុដើមពិសេស ដែលអាចប្រឆាំង ការពារការឆាបឆេះ ដែលជាសមត្ថភាពដ៏ពិសេស សម្រាប់ប្រើប្រាស់ចំពោះប្រព័ន្ធភ្លើង គ្រប់ប្រភេទ និងអាចការពារគ្រោះមហន្តរាយនានាដែលបង្កពីការទុស្សេខ្សែភ្លើង។

### ទន់ងាយស្រួលបត់បែន

អាចបត់បែនបានគ្រប់កាលៈទេសៈដែលសក្តិសមបំផុត សម្រាប់គ្រប់រចនាបថនៃសំណង់ទំនើប អគារ និងគ្រប់សហគ្រាសតូចធំ។

### មិនចម្លងអគ្គិសនី

ផលិតពីសារធាតុជ័រល្អ ប្រភពដើមពីអឺរ៉ុប គ្មានជាតិលោហៈ និងមិនចម្លងចរន្តអគ្គិសនី បង្កើនសុវត្ថិភាពខ្ពស់ ចំពោះគ្រោះថ្នាក់ឆក់ចរន្តអគ្គិសនី ដែលល្អប្រសើរបំផុតក្នុងការប្រើប្រាស់សម្រាប់ដំឡើងប្រព័ន្ធអគ្គិសនីច្រើនសណ្ឋាន។

### ការពារកាំរស្មី UV និងអាស៊ីត

មានប្រសិទ្ធិភាពខ្ពស់ធន់នឹងកាំរស្មី UV និងអាស៊ីតខ្សោយ ដែលសក្តិសមបំផុតសម្រាប់ប្រើប្រាស់ រ៉ៃខ្សែភ្លើងទាំងក្នុង និងក្រៅអគារ។

### ស្រាល

ទុយោស៊ីក និងហ្គេនខ្សែភ្លើង ជីប ម៉ុង មានទម្ងន់ស្រាល ការវេចខ្ចប់មានសណ្តាប់ធ្នាប់ ដែលងាយស្រួលក្នុងការដឹកជញ្ជូន ឬទុកដាក់។
















# សុវត្ថិភាពជាចម្បង

## ១២ ចំណុច ច្បាប់មូលដ្ឋានសម្រាប់សុវត្ថិភាពការងារ

### ១. ឧបករណ៍សុវត្ថិភាព




### ២. កន្លែងចង្អៀត




### ៣. គោលការណ៍ និងការអនុញ្ញាត




### ៤. ការធ្លាក់ពីទីខ្ពស់ និងខ្សែក្រវ៉ាត់



### ៥. ការលើកដាក់ទំនិញ



### ៦. ផ្លាកសញ្ញាការពារពេលជួសជុល



### ៧. ការស្ទូចទំនិញ




### ៨. សុវត្ថិភាពនៅពេលបើកបរ



### ៩. ច្បាប់ចរាចរណ៍



### ១០. ការប្រើប្រាស់គ្រឿងស្រវឹង



### ១១. ខ្សែក្រវ៉ាត់រថយន្ត



### ១២. រាយការណ៍

